# របាំត្រុដិ

**របាំត្រុដិ** មានរៀបរាប់នៅក្នុងព្រះរាជពិធីហៅថា «ត្រស្តិសង្ក្រាន្ត» (អានថា «ត្រស់សង្ក្រាន្ត»)។[១] នាអតីតកាល ឃើញច្រើននៅក្នុងខេត្តសៀមរាបនិងខេត្តបាត់ដំបង និងសព្វថ្ងៃនៅក្នុងទីក្រុងភ្នំពេញដែរ **របាំត្រុដិ** មានប្រភពដើមចេញពីរឿងព្រេងនិងកត្តាផ្សេងៗមួយចំនួនមាន៖ ឫសគល់នៃពាក្យ «ត្រុដិ» រឿងនិទាន រឿងសាសនា ជំនឿ និងការស្រាវជ្រាវ។[២]

**របាំត្រុដិ** មានតួសម្តែងរួមមាន សត្វប្រើស ព្រានព្រៃ យក្ស ព្រាយស្រីក្រចកវែង សត្វក្ងោក សត្វទន្សោង កំដរដោយអ្នកវាយស្គរដៃ អ្នកបុកកញ្ជែរ (កញ្ជារ) និងកញ្ចាំ និងអ្នកច្រៀងគោលដឹករបាំ ហើយច្រៀងបន្ទរដោយអ្នកសម្តែងទាំងអស់គ្នា។ ពាក្យពេចន៍ប្រើនៅក្នុងចម្រៀងមានភាពខុសគ្នាទៅតាមក្រុមសម្តែង។ យោងតាមឯកសាររបស់សម្តេចព្រះវណ្ណរត្ន អ៊ីវ ទូត នៅខេត្តបាត់ដំបង ពាក្យពេចន៍នៃរបាំត្រុដិ បែកជាបួនផ្នែក៖ (១) ការមកដល់នៃរបាំ (២) ការសុំទាននិងបច្ច័យ (៣) ការប្រមូលទាននិងបច្ច័យ និង (៤) ការថ្លែងអំណរគុណនិងជូនពរដល់អ្នកផ្តល់ទាននិងបច្ច័យ។[៣]

គេសម្តែង**របាំត្រុដិ** នៅពេលបុណ្យចូលឆ្នាំ ដើម្បីប្រមូលថវិកាទ្រទ្រង់វត្តអារាម ដើម្បីកំចាត់ឧបទ្រពចង្រៃ ដើម្បីសុំទឹកភ្លៀង និងដើម្បីឆ្លងពីឆ្នាំចាស់មកឆ្នាំថ្មីប្រកបដោយសិរីសួស្តីជ័យមង្គល ដែលជានិយមន័យនៃពាក្យ «ត្រុដិ-ត្រស្តិ» នេះឯង។ ជារឿយៗផងដែរ នៅខេត្តសៀមរាប ក្នុងរដូវរាំងស្ងួត គេមានជំនឿថា សត្វប្រើសជាសភាវៈអាក្រក់ដែលធ្វើឱ្យមានការរាំងស្ងួត។ ដូច្នេះសត្វប្រើសត្រូវគេសម្លាប់ដើម្បីឲ្យប្រជាពលរដ្ឋអ្នកស្រុកភូមិបានទទួលនូវទឹកភ្លៀងនិងភាពសម្បូណ៌សប្បាយឡើងវិញ។ នៅក្នុងតំបន់ខ្លះ មានស្រុកសូត្រនិគមនិងតំបន់ភ្នំគូលែន គេសម្តែងរបាំត្រុដិនៅពេលក្តៅហួតហែងដែលមានវគ្គត្រង់សត្វ

---

[១] ជួន ១៩៦៧: ៣៦៨/៣៩២, ចាប ១៩៦៤: ៩

[២] សំ ១៩៩៨: ៣៨-៤៧

[៣] ចាប ១៩៦៤: ២១-២៧

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ប្រើសស្លាប់។ ក្រោយពីសត្វប្រើសស្លាប់ហើយ គេក៏យកទឹកមកចាក់ស្រោចលើសត្វប្រើស ជានិមិត្តរូបនៃការទទួលបាននូវទឹកភ្លៀង។

ក្នុងជំនឿបុរាណខ្មែរ សត្វប្រើសតំណាងឱ្យសភាវៈអាក្រក់។ ជំនឿនេះ មានរៀបរាប់នៅក្នុងរឿងព្រេងនិងការអនុវត្តជាក់ស្តែងដូចជារឿងរាមកេរ្តិ៍ ត្រង់ឈុត «ព្រះរាមដើរទេស» ដែលរាពណ៍បញ្ជាឱ្យមហារីកកាឡាខ្លួនជាសត្វប្រើសមាស (សភាវៈអាក្រក់) ទៅបញ្ឆោតនាងសីតា។

នៅពេលចូលឆ្នាំខ្មែរ គេសម្តែងរបាំត្រុដិ ដែលបញ្ចប់ដោយការបាញ់សត្វប្រើសស្លាប់ ដើម្បីបញ្ចប់ឆ្នាំចាស់ និងអនុញ្ញាតឱ្យឆ្នាំថ្មីចូលនិងនាំមកនូវសិរីសួស្តីជ័យមង្គលដល់ប្រជាពលរដ្ឋខ្មែរ។ នៅរដូវចូលឆ្នាំខ្មែរ គេសម្តែងរបាំត្រុដិពីផ្ទះមួយទៅផ្ទះមួយក្នុងរយៈពេលរាប់ម៉ោង ដោយមានមនុស្សប្រុសស្រីចាស់ក្មេងដើរតាមជាក្បួននិងក្រុមដើម្បីប្រមូលបច្ច័យជាប្រាក់យកទៅទ្រទ្រង់វត្តអារាម។

ការសម្តែងរបាំត្រុដិនៅក្នុងសហគមន៍ខ្មែរ មិនមែនជារបររកស៊ីឡើយ តែជាសកម្មភាពអភិវឌ្ឍន៍សហគមន៍ និងការចូលរួមថែរក្សាទំនៀមទម្លាប់ប្រពៃណីនិងវប្បធម៌ខ្មែរឱ្យគង់វង្សទៅអនាគត។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង








KHMER CIVILIZATION

## ឯកសារពិគ្រោះ


ចាប ពិន

១៩៦៤. *របាំប្រជាប្រិយខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ជួន ណាត

១៩៦៧. *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang.

1998. *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង